## Requesting and granting permission 2



**នៅហាងលក់កាបូប**

ស្រីរ័ត្ន៖ បង ខ្ញុំសុំមើលកាបូបនោះតិចបានអេ៎?
អ្នកលក់៖ មើលបានតាសអូន។ អាមួយនោះមែន?
ស្រីរ័ត្ន៖ ចាំស
អ្នកលក់៖ ម៉ូតហ្នឹងទើបតែម៉ោថ្មី។

**នៅហាងលក់គ្រឿងអគ្គិសនី**

ស្រីរ័ត្ន៖ បង ខ្ញុំអាចសាកប្រើទូរទស្សន៍នេះតិចបានអេ៎? ជួយប្រាប់ពីរបៀបប្រើផង។
អ្នកលក់៖ បាទ សាកប្រើចុះអូន។ ចាំខ្ញុំពន្យល់ពីរបៀបប្រើ។

**នៅហាងលក់សម្លៀកបំពាក់ (= ហាងលក់ខោអាវ)**

ស្រីរ័ត្ន៖ អូន ខ្ញុំសុំលអាវនេះតិចបានអេ៎? ខ្លាចទិញទៅពាក់អត់ត្រូវ។
អ្នកលក់៖ ចាំស បានបង។ នោះបន្ទប់ល។

| | |
|---|---|
| ស្រីរ័ត្ន | female Cambodian name |
| អេ៎ | spoken form of the question particle ទេ |
| តាស | used to affirm the preceding |
| អាមួយនោះ | that one |
| ម៉ោ | spoken form of មក = to come |
| សាកប្រើចុះអូន | Go ahead and try it! |
| ពាក់អត់ត្រូវ | clothes: doesn't fit |

## Cultural notes

ការទិញអីវ៉ាន់នៅខ្មែររៀងពិបាកបន្តិច ព្រោះអ្នកលក់មិនសូវចង់ឲ្យភ្ញៀវប៉ះពាល់ ឬល
ឬសាកល្បងទំនិញរបស់គេច្រើនទេមុននឹងទិញ។ បើភ្ញៀវទិញទំនិញនោះក្រោយពេលប៉ះពាល់ នោះមិនអីទេ

Copyright © 2017 www.aakanee.com – This document is provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ប៉ុន្តែបើមិនទិញវិញ នោះអ្នកលក់អាចនឹងសម្តែងទឹកមុខមិនពេញចិត្ត។
ទំនិញដូចជាខោអាវដែលលក់នៅតាមផ្សារ សឹងតែ ៥០ ភាគរយគឺមិនបានបិទផ្លាកតម្លៃនោះទេ
ហើយបើគ្រាន់តែសួរតម្លៃទំនិញហើយដើរចេញ នោះកាន់តែធ្វើឲ្យអ្នកលក់មិនពេញចិត្ត។

| | |
|---|---|
| រៀង ... បន្តិច | a little bit [difficult etc.] |
| ប៉ះពាល់ | to touch |
| នោះ | phrase-initial: then, e.g., នោះមិនអីទេ = then it’s no problem |
| សម្តែងទឹកមុខ [...] | to make a [...] face, to show the expression of [...] |
| សឹងតែ ... ភាគរយ | almost ... percent |
| បិទ | to paste, put on |
| ផ្លាកតម្លៃ | price tag |
| កាន់តែ | even |

## Additional dialogue

នៅហាងអាហារ

ភ្ញៀវ៖ អេ អូន។ សុំមីនុយ / យកមីនុយម៉ោតិចមើល។
អ្នករត់តុ៖ បាទ បង។ នេះមីនុយ។
...
ភ្ញៀវ៖ អេ អូន កុម្ម៉ង់បានអេ៎?
អ្នករត់តុ៖ បាទ បង។ ត្រូវការអីគេដែរ?
ភ្ញៀវ៖ យកទឹកក្រឡុកមួយកែវ សុំកុំដាក់ទឹកដោះគោបានអត់?
អ្នករត់តុ៖ បានតាសបង ចាំខ្ញុំប្រាប់គេឲ្យ។
ភ្ញៀវ៖ ហើយជួយយកកៅអីថែមមក ២ ទៀតម៉ោបានអេ៎? តិចទៀតមានពួកម៉ាកម៉ោ ២ នាក់ទៀត។
អ្នករត់តុ៖ បាទ។
ភ្ញៀវ៖ នៅហ្នឹងអាចយកនំខួបកំណើតអីចូលបានអេ៎?
អ្នករត់តុ៖ នំខួបកំណើតយកចូលបានបង តែនំញ៉ាំធម្មតាយកចូលអត់បានអេ៎បង។

| | |
|---|---|
| ហាងអាហារ | = ភោជនីយដ្ឋាន = ហាងបាយ = restaurant |
| មីនុយ | menu |
| ទឹកក្រឡុក | fruit shake (4 or 5 kinds of fruit, sticky milk, syrup, ice) |
| ទឹកដោះគោ | milk, here the speaker refers to sticky milk (ទឹកដោះគោខាប់) |
| ពួកម៉ាក | friend |
| ... អី | ... something like that / ... or so |

Copyright © 2017 www.aakanee.com – This document is provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.